**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**'រ.ទ.ស.ភ'**

លេខ ...០៣៣០..ល.ផ.៧

ភ្នំពេញ, ថ្ងៃទី ២៧ ខែ ០១ ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់បំពង់ជ័រប៉េអឺ, រថយន្តរដ្ឋបាល, សម្ភារតភ្ជាប់ប៉េអឺ, បំពង់ប៉េវេសេ និងសម្ភារតភ្ជាប់ និង អំបិលសមុទ្រសម្រាប់ផលិតក្លរ័ទឹក

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់នូវទំនិញ ដូចខាងក្រោម:

១-កញ្ចប់"ក": ការផ្គត់ផ្គង់បំពង់ជ័រប៉េអឺ
២-កញ្ចប់"ខ": ការផ្គត់ផ្គង់រថយន្តរដ្ឋបាល ចំនួន២គ្រឿង
៣-កញ្ចប់"គ": ការផ្គត់ផ្គង់សម្ភារតភ្ជាប់ប៉េអឺ
៤-កញ្ចប់"ឃ": ការផ្គត់ផ្គង់បំពង់ប៉េវេសេ និងសម្ភារតភ្ជាប់
៥-កញ្ចប់"ង": ការផ្គត់ផ្គង់អំបិលសមុទ្រសម្រាប់ផលិតក្លរ័ទឹក

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០ព្រឹកដល់១៦:៣០ល្ងាច) ក្នុងមួយច្បាប់តម្លៃ ៣០០,០០០រៀល សម្រាប់កញ្ចប់ "គ", ២០០,០០០រៀល សម្រាប់កញ្ចប់ "ក,ខ" និង១២០,០០០រៀល សម្រាប់កញ្ចប់ "ឃ,ង"។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ កញ្ចប់"ក"វេលាម៉ោង ១៤:៣០នាទី, កញ្ចប់"ខ"វេលាម៉ោង១៤:៥០នាទី, កញ្ចប់"គ"វេលាម៉ោង១៥:១០នាទី, កញ្ចប់"ឃ"វេលាម៉ោង១៥:៣០នាទី និងកញ្ចប់"ង" វេលាម៉ោង ១៥:៥០នាទី នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃមិនតិចជាង២% (ពីរភាគរយ) នៃតម្លៃដាក់ដេញសរុប។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត ជា វិសុទ្ធ**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទ: ៨៥៥(២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh

KINGDOM OF CAMBODIA
NATION RELIGION KING

PHNOM PENH
WATER SUPPLY AUTHORITY
"PPWSA"
№.....030 PPWSA

Date.....26, Jan, .....2017

## Invitation for Bids

Phnom Penh Water Supply Authority (PPWSA) now invites sealed bids from eligible Bidders registered in the Kingdom of Cambodia for the **Supply and Delivery of:**

1-Package "A": High Density Polyethylene Pipes

2-Package "B": SUV Vehicle

3-Package "C": High Density Polyethylene Fittings

4-Package "D": PVC Pipes and Fittings

5-Package "E": Salt for the Production of Sodium Hypochlorite

The bidder shall furnish with his bid the copy of Patent, Certification of Incorporation, and Certificate of VAT Registration legalized by Phnom Penh Municipality. All bids must be accompanied by a bid security in an amount not less than two percent (2%) of the total bid price.

A complete set of bidding document is available upon payment of non-refundable fee of 300,000Riels for Package "C", 200,000Riels for Package "A,B" and 120,000Reils for Package "D,E" at Procurement Unit of PPWSA with the address #45, Street 106, Sangkat Srash Chork, Khan Daun Penh, Phnom Penh, working hour from 08:00am to 16:30pm.

Completed bids must be delivered to the address above at or before 14:30pm Package "A", 14:50pm Package "B", 15:10pm Package "C", 15:30pm Package "D" and 15:50pm Package "E" on 09th March 2017. Late bids will be rejected.

Bids will be opened in the present of the bidders' representatives who choose to attend at the address above (1st Floor of Procurement Building) at **14:30pm Package "A", 14:50pm Package "B", 15:10pm Package "C", 15:30pm Package "D" and 15:50pm Package "E" on 09th March 2017.**

Associated bidders are allowed to submit only one bid.

Interested eligible bidders may obtain further information from Procurement Unit of PPWSA at the address above or phone number: 017 811 911.